លេខ ៣៩ ចេញផ្សាយថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០២៤

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែសីហា ឆ្នាំ២០២៤

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## មាតិកា


- កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងចុងក្រោយ នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០ ទំព័រទី១
- កិច្ចប្រជុំពិភាក្សាលើការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ និងគោលនយោបាយនានា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទំព័រទី២
- ទស្សនកិច្ចសិក្សាស្តីពី “ការប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)” នៅព្រះរាជាណាចក្រថៃឡង់ដ៍ ទំព័រទី២
- ពិធីបើកការដ្ឋានសាងសង់ “ព្រែកជីកហ្វូណនតេជោ” ទំព័រទី៣
- កិច្ចប្រជុំពិនិត្យពិភាក្សាលើការងារពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទំព័រទី៣
- សិក្ខាសាលាស្តីពី “ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍” នៅខេត្តកំពង់ចាម ទំព័រទី៣
- ប្រជុំពិភាក្សាការងារអំពីការរៀបចំក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ សម្រាប់វិស័យបរធនបាលកិច្ច ទំព័រទី៤
- ការបន្តការងារផ្សព្វផ្សាយពាក់ព័ន្ធនឹងផលិតផលឥណទានក្នុងគម្រោងដល់សមាជិកសហគមន៍ ទំព័រទី៤
- កិច្ចប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំ លើគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទំព័រទី៥
- កិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ទំព័រទី៥
- កិច្ចប្រជុំកំពូលសេដ្ឋកិច្ចពិភពលោកលើកទី៩ ស្តីពី "បច្ចេកវិទ្យាហិរញ្ញវត្ថុ÷ការពន្លឿនបដិវត្តន៍ឌីជីថល" នៅមជ្ឈមណ្ឌលពិព័រណ៍ មជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោក ទីក្រុងម៉ុមបៃ ប្រទេសឥណ្ឌា ទំព័រទី៦
- កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ទំព័រទី៦
- ពិធីអនុស្សរណៈនៃការយោគយល់គ្នារវាង ន.ប.ធ.និងក្រុមហ៊ុន ស្រ្តងហ្វូល ត្រាសធី ឯ.ក ទំព័រទី៧
- សិក្ខាសាលាពិគ្រោះយោបល់លើកទី២ លើសេចក្តីព្រាង “យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥” ទំព័រទី៧
- កិច្ចប្រជុំអន្តរអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទំព័រទី៨
- សិក្ខាសាលាស្តីពី “ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច” ទំព័រទី៨
- វេទិកាស្តីពី “ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍ និងកសិករចិញ្ចឹមមាន់ស្រុក” នៅខេត្តត្បូងឃ្មុំ ទំព័រទី៨
- ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ទំព័រទី៩
- ទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍នៅប្រទេសម៉ាឡេស៊ី ទំព័រទី៩
- ការបន្តការងារផ្សព្វផ្សាយពាក់ព័ន្ធនឹងផលិតផលឥណទានក្នុងគម្រោងដល់សមាជិកសហគមន៍ ទំព័រទី១០
- ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង ន.ប.ធ. និងក្រុមហ៊ុន អាយជី ថិក គ្រុប ទំព័រទី១១
- កិច្ចប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំលើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទំព័រទី១១
- ប្រជុំពិភាក្សាការងាររវាង ន.ប.ធ. ជាមួយក្រសួងមហាផ្ទៃ ទំព័រទី១២
- កិច្ចប្រជុំវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តគម្រោង ACSEP សមាសភាគទី១ ទំព័រទី១២
- កិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ទំព័រទី១៣
- សិក្ខាសាលាស្តីពី “ច្បាប់ស្តីពីបរធនបាលកិច្ច និងនិន្នាការថ្មីៗពាក់ព័ន្ធអចលនវត្ថុ” ទំព័រទី១៣
- សិក្ខាសាលាពិគ្រោះយោបល់លើកទី៣ លើសេចក្តីព្រាង “យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥” ទំព័រទី១៣
- ពិធីសម្បថរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ចរបស់និយ័តករបរធនបាលកិច្ច ទំព័រទី១៤
- ការប្រឡងជ្រើសរើសមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារសម្រាប់ចូលបម្រើការងារនៅ ន.ប.ធ. ទំព័រទី១៤
- កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទំព័រទី១៥


## កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងចុងក្រោយ នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០

នារសៀលថ្ងៃព្រហស្បតិ៍ ១២រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១ ខែសីហា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយក នៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) និងជាសមាជិកគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងចុងក្រោយ នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០ នៅធនាគារជាតិនៃកម្ពុជា ក្រោមអធិបតីភាពរបស់ **លោកជំទាវបណ្ឌិត ជា សិរី** ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា និងជាប្រធានគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាសមាជិក-សមាជិកាគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ។



រូបភាព៖ កិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងចុងក្រោយ នៃយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០២១-២០៣០។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំពិភាក្សាលើការងារតាមដាន ត្រួតពិនិត្យ និង វាយតម្លៃ ការអនុវត្តយុទ្ធសាស្ត្រផែនការអភិវឌ្ឍន៍ និង គោលនយោបាយនានា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នាព្រឹកថ្ងៃសុក្រ ១៣រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២ ខែសីហា ឆ្នាំ២០២៤ **ឯកឧត្តម ណី សាភល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ ន.ប.ធ. អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាលើការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តយុទ្ធសាស្ត្រផែនការអភិវឌ្ឍន៍ និង គោលនយោបាយនានា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តយុទ្ធសាស្ត្រ ផែនការអភិវឌ្ឍន៍ និងគោលនយោបាយនានា (កឃផគ)។ កិច្ចប្រជុំនេះ មានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាសមាជិកនៃ កឃផគ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



*រូបភាព៖* កិច្ចប្រជុំពិភាក្សាលើការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការអនុវត្តយុទ្ធសាស្ត្រផែនការអភិវឌ្ឍន៍ និងគោលនយោបាយនានា នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ទស្សនកិច្ចសិក្សាស្តីពី "ការប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)" នៅព្រះរាជាណាចក្រថៃឡង់ដ៍

នាថ្ងៃអាទិត្យ ៨រោច ដល់ថ្ងៃសៅរ៍ ១៤រោច ខែអាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែកក្កដា ដល់ថ្ងៃទី៣ ខែសីហា ឆ្នាំ២០២៤ ដោយមានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) និងជាប្រធានគ្រប់គ្រងគម្រោងនៃគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP) សមាសភាគទី១ ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, **លោក ឆែម លាបហេង** ប្រធានការិយាល័យអធិការកិច្ច និងពង្រឹងការអនុវត្តច្បាប់ និងជាមន្ត្រីផ្នែកប្រតិបត្តិការនៃគម្រោង ACSEP បានអញ្ជើញចូលរួមទស្សនកិច្ចសិក្សាស្តីពី "ការប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)" នៅព្រះរាជាណាចក្រថៃឡង់ដ៍។

ទស្សនកិច្ចសិក្សានេះ ដឹកនាំដោយ **លោក ឆេង វិបុលរិទ្ធិ** ជាប្រធានអង្គភាពគ្រប់គ្រងគម្រោង នៃអង្គភាពអនុវត្តគម្រោងសមាសភាគទី២ ក្នុងក្របខណ្ឌក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការចូលរួមពីតំណាងក្រសួងអភិវឌ្ឍន៍ជនបទ និងនាយកដ្ឋានជំនាញចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សរុបចំនួន ២៨ រូប។



*រូបភាព៖* ទស្សនកិច្ចសិក្សាស្តីពី "ការប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP)" នៅព្រះរាជាណាចក្រថៃឡង់ដ៍។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## ពិធីបើកការដ្ឋានសាងសង់ "ព្រែកជីកហ្វូណនតេជោ"

ព្រឹកថ្ងៃចន្ទ ១កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែសីហា ឆ្នាំ២០២៤, និយ័តករបរធនបាលកិច្ច (ន.ប.ធ.) បានចូលរួមអបអរសាទរយ៉ាងអធិកអធម កុះករ គ្រៀវក្លា ក្នុងពិធីបើកការដ្ឋានសាងសង់ "ព្រែកជីកហ្វូណនតេជោ" ដោយ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ ន.ប.ធ. បានអញ្ជើញចូលរួមដោយផ្ទាល់ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងសហការីនៃ ន.ប.ធ. បានចូលរួមអបអរសាទរជាមួយអគ្គលេខាធិការដ្ឋាន និយ័តករ និងអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) នៅទីស្តីការ អ.ស.ហ. ដើម្បីគាំទ្រគម្រោងដែលផ្តល់ផលប្រយោជន៍ដ៏មហាសាលដល់សង្គម និងសេដ្ឋកិច្ចកម្ពុជា ជាពិសេសគឺជាមរតកប្រវត្តិសាស្ត្រសម្រាប់កូនចៅជំនាន់ក្រោយរបស់យើងទាំងអស់គ្នា ក្នុងស្មារតី "គម្រោងរបស់ខ្មែរទាំងអស់គ្នា ដោយខ្មែរនិងដើម្បីខ្មែរគ្រប់រូប"។



រូបភាព៖ ពិធីបើកការដ្ឋានសាងសង់ "ព្រែកជីកហ្វូណនតេជោ"។

## កិច្ចប្រជុំពិនិត្យពិភាក្សាលើការងារពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នារសៀលថ្ងៃពុធ ៣កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យពិភាក្សាលើការងារពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមមាស សុខសេនសាន** រដ្ឋលេខាធិការ កសហវ និងជាប្រធានក្រុមការងារពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធរបស់ កសហវ និងមានការអញ្ជើញចូលរួមពីតំណាងក្រសួងមុខងារសាធារណៈ ព្រមទាំង ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាថ្នាក់ដឹកនាំតំណាងស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងក្របខណ្ឌ កសហវ នៅទីស្តីការ កសហវ។



រូបភាព៖ កិច្ចប្រជុំពិនិត្យពិភាក្សាលើការងារពិនិត្យឡើងវិញ និងការវិភាគមុខងារនិងរចនាសម្ព័ន្ធក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍" នៅខេត្តកំពង់ចាម

នាថ្ងៃពុធ ៣កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែសីហា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍" នៅខេត្តកំពង់ចាម ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 និងអភិបាលរងនៃគណៈអភិបាលស្រុកព្រៃឈរ ខេត្តកំពង់ចាម។

កម្មវិធីនេះត្រូវបានរៀបចំនៅសហគមន៍ចំនួន ២ រួមមាន៖ សហគមន៍កសិកម្មអភិវឌ្ឍន៍ស្រុកយើង និងសហគមន៍កសិកម្មអភិវឌ្ឍន៍កសិករ ក្នុងគោលបំណងធ្វើការណែនាំបន្ថែមដល់សមាជិកសហគមន៍ និងភ្នាក់ងារឥណទានគម្រោង ACSEP តាមខេត្ត ស្រុក និងឃុំគោលដៅ, ផ្តល់ព័ត៌មានអំពីការផ្តល់ប្រាក់កម្ចី របស់គម្រោង ACSEP ដល់សមាជិកសហគមន៍កសិកម្មដែលមានក្នុងបញ្ជីក្រុមគោលដៅ និងកសិករចិញ្ចឹមមាន់ស្រុក និងបង្ហាញអំពីនីតិវិធីដែលអាចទទួលបានឥណទានដល់សមាជិកសហគមន៍កសិកម្ម ដែលមានបំណងស្វែងរកទុនគាំទ្រផែនការអាជីវកម្មលើវិស័យកសិកម្ម។

កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម, អភិបាលរងស្រុក, ក្រុមប្រឹក្សាឃុំ, មេភូមិ និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888





រូបភាព៖ សិក្ខាសាលាស្ដីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍" នៅខេត្តកំពង់ចាម។

## ប្រជុំពិភាក្សាការងារអំពីការរៀបចំក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ សម្រាប់វិស័យធនបាលកិច្ច

នាព្រឹកថ្ងៃសុក្រ ៥កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករធនបាលកិច្ច (**ន.ប.ធ**) អមដោយសហការីបានដឹកនាំប្រជុំពិភាក្សាការងារអំពីការរៀបចំក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ សម្រាប់វិស័យធនបាលកិច្ច ជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល (**គ.ស.ធ.ឌ.**) ដែលតំណាងដោយ **លោកជំទាវ ផល ម៉ារីណា** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន **គ.ស.ធ.ឌ.** អមដោយសហការី នៅមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច ជាន់ទី១៧។ កិច្ចប្រជុំនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងសំខាន់ចំនួន ៣ គឺ៖ ១). សិក្សា និងស្វែងយល់បន្ថែមពីក្របខណ្ឌតាមដាន និងវាយតម្លៃ របស់ **ន.ប.ធ.**, ២). ប្រមូលធាតុចូល និងមតិយោបល់ក្នុងការរៀបចំក្របខណ្ឌតាមដាន និងវាយតម្លៃការអនុវត្តគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ និង ៣). បង្កើនកិច្ចសហការក្នុងការរៀបចំក្របខណ្ឌតាមដាន និងវាយតម្លៃឱ្យកាន់តែស៊ីជម្រៅ និងមានភាពប្រទាក់ក្រឡាគ្នាទៅវិញទៅមក។



រូបភាព៖ ប្រជុំពិភាក្សាការងារអំពីការរៀបចំក្របខណ្ឌតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ សម្រាប់វិស័យធនបាលកិច្ច។

## ការបន្តការងារផ្សព្វផ្សាយពាក់ព័ន្ធនឹងផលិតផលឥណទានក្នុងគម្រោងដល់សមាជិកសហគមន៍

ចាប់ពីថ្ងៃព្រហស្បតិ៍ ៤កើតដល់ថ្ងៃសុក្រ ៥កើតខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៨-៩ ខែសីហា ឆ្នាំ២០២៤ និយ័តករធនបាលកិច្ច ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP-PIU1) ក្រោមក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបន្តការងារផ្សព្វផ្សាយពាក់ព័ន្ធនឹងផលិតផលឥណទានក្នុងគម្រោងដល់សមាជិកសហគមន៍ នៅថ្ងៃទី៨ ខែសីហា ឆ្នាំ២០២៤ ដល់សហគមន៍កសិកម្មសំបូរមានជ័យ និងសហគមន៍កសិកម្មស្ទឹងត្រង់សែនជ័យ និងនៅថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៤ ដល់សហគមន៍កសិកម្មពន្លកថ្មី នៅខេត្តកំពង់ចាម ក្រោមការដឹកនាំរបស់ **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1។

កម្មវិធីនេះត្រូវបានរៀបចំក្នុងគោលបំណងធ្វើការណែនាំបន្ថែមដល់សមាជិកសហគមន៍ និងភ្នាក់ងារឥណទានគម្រោង ACSEP តាមខេត្ត ស្រុក និងឃុំគោលដៅ, ផ្តល់ព័ត៌មានអំពីការផ្តល់ប្រាក់កម្ចីរបស់គម្រោង ACSEP ដល់សមាជិកសហគមន៍កសិកម្មដែលមានក្នុងបញ្ជីក្រុមគោលដៅ និងកសិករចិញ្ចឹមមាន់ស្រុក និងបង្ហាញអំពីនីតិវិធីដែលអាចទទួលបានឥណទានដល់សមាជិកសហគមន៍កសិកម្មដែលមានបំណងស្វែងរកទុនគាំទ្រផែនការអាជីវកម្មលើវិស័យកសិកម្ម។

កម្មវិធីខាងលើ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, ប្រធាន-អនុប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម, ក្រុមប្រឹក្សាឃុំ, មេភូមិ និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីររួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



រូបភាព៖ ការបន្តការងារផ្សព្វផ្សាយពាក់ព័ន្ធនឹងផលិតផលឥណទានក្នុងគម្រោងដល់សមាជិកសហគមន៍។

## កិច្ចប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំ លើគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នារសៀលថ្ងៃសុក្រ ៥កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែសីហា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) អមដោយ **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅនៃ **ន.ប.ធ.** និងមន្ត្រីជំនាញ បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំលើគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) នៅទីស្តីការ **កសហវ** ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ចាន់ សុធី** រដ្ឋលេខាធិការនៃ **កសហវ** និង **ឯកឧត្តម មាស សុខសេនសាន** រដ្ឋលេខាធិការនៃ **កសហវ**។ កិច្ចប្រជុំនេះមានការអញ្ជើញចូលរួមដោយផ្ទាល់ពីថ្នាក់ដឹកនាំនៃ **កសហវ** ព្រមទាំងថ្នាក់ដឹកនាំអង្គភាពថវិកាស្ថិតក្រោមឱវាទ **កសហវ**។



រូបភាព៖ កិច្ចប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំ លើគម្រោងចំណូល-ចំណាយថវិកាឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## កិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

នារសៀលថ្ងៃចន្ទ ៨កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១២ ខែសីហា ឆ្នាំ២០២៤ តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.), **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ និង **លោកស្រី ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច ព្រមទាំងសហការី បានចូលរួមកិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា **អ.ស.ហ.** និងមានការអញ្ជើញចូលរួមពីនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ Zoom។

កិច្ចប្រជុំនេះរៀបចំឡើងក្នុងគោលបំណង ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងចំនួន ៣ រួមមាន៖ (១).សេចក្តីព្រាងអនុក្រឹត្យស្តីពី ការបំពាក់មុខងារបន្ថែមឱ្យមជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** ជាអង្គភាពបរិវត្តកម្មឌីជីថលនៃ **អ.ស.ហ.**, (២).សទ្ទានុក្រមគណនេយ្យនិងសវនកម្ម ក្នុងក្របខណ្ឌស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូច និងមធ្យមរបស់ **ន.គ.ស.** និង (៣).សេចក្តីព្រាងប្រកាសស្តីពី ការដាក់ទណ្ឌកម្មខាងវិន័យចំពោះបុគ្គលរាយការណ៍ក្នុងវិស័យមូលបត្រ ដែលមិនអនុវត្តតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម របស់ **ន.ម.ក.**។



រូបភាព៖ កិច្ចប្រជុំបច្ចេកទេសនៃអង្គភាពក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## កិច្ចប្រជុំកំពូលសេដ្ឋកិច្ចពិភពលោកលើកទី៩ ស្តីពី "បច្ចេកវិទ្យាហិរញ្ញវត្ថុ៖ ការពន្លឿនបដិវត្តន៍ឌីជីថល" នៅមជ្ឈមណ្ឌលពិព័រណ៍ មជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោក ទីក្រុងម៉ុមបៃ ប្រទេសឥណ្ឌា

ចាប់ពីថ្ងៃពុធ ៨ កើត ដល់ថ្ងៃសៅរ៍ ៦ កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៨-១០ ខែសីហា ឆ្នាំ២០២៤ **ឯកឧត្តម ណី សារាកល** អគ្គនាយករងនៃនិយ័តករបេឡាធនបាលកិច្ច (ន.ប.ធ.) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលសេដ្ឋកិច្ចពិភពលោកលើកទី៩ ស្តីពី "បច្ចេកវិទ្យាហិរញ្ញវត្ថុ៖ ការពន្លឿនបដិវត្តន៍ឌីជីថល" នៅមជ្ឈមណ្ឌលពិព័រណ៍ មជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោក ទីក្រុងម៉ុមបៃ ប្រទេសឥណ្ឌា។ កិច្ចប្រជុំកំពូលសេដ្ឋកិច្ចនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីបង្ហាញអំពីនវានុវត្តន៍ថ្មីៗនៃបច្ចេកវិទ្យានៅក្នុងវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ (Fintech) និងផ្តល់ឱកាសក្នុងការផ្សព្វផ្សាយ ការភ្ជាប់បណ្តាញទំនាក់ទំនង ការផ្លាស់ប្តូរគំនិត និងការអភិវឌ្ឍធុរកិច្ចនៅក្នុងបរិបទសេដ្ឋកិច្ចឌីជីថល។ នាឱកាសនេះ **ឯកឧត្តម ណី សារាកល** ត្រូវបានអញ្ជើញចូលរួមជាវាគ្មិនកិត្តិយសក្នុងកិច្ចពិភាក្សាពាក់ព័ន្ធនឹងការចាប់យកឱកាសក្នុងទីផ្សារ និងការសហការជាមួយអ្នកជំនាញអន្តរជាតិ ដើម្បីពង្រីកធុរកិច្ចទៅក្រៅប្រទេសផងដែរ។ កិច្ចប្រជុំកំពូលសេដ្ឋកិច្ចនេះមានការអញ្ជើញចូលរួមពីវាគ្មិនកិត្តិយស និងអ្នកជំនាញជាន់ខ្ពស់នៃស្ថាប័នអន្តរជាតិពាក់ព័ន្ធក្នុងវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ ដែលមកពីបណ្តាប្រទេសផ្សេងៗ រួមមានជាអាទិ៍ ប្រទេសឥណ្ឌា, ប្រទេសជប៉ុន, ប្រទេសហ្វីលីពីន និងប្រទេសលុចសំបួ ព្រមទាំងមជ្ឈមណ្ឌលពាណិជ្ជកម្មអន្តរជាតិ ទីក្រុងហ្សឺណែវ។




រូបភាព៖ កិច្ចប្រជុំកំពូលសេដ្ឋកិច្ចពិភពលោកលើកទី៩ ស្តីពី "បច្ចេកវិទ្យាហិរញ្ញវត្ថុ៖ ការពន្លឿនបដិវត្តន៍ឌីជីថល" នៅមជ្ឈមណ្ឌលពិព័រណ៍ មជ្ឈមណ្ឌលពាណិជ្ជកម្មពិភពលោក ទីក្រុងម៉ុមបៃ ប្រទេសឥណ្ឌា។

## កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

រសៀលថ្ងៃពុធ ១០កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៤ខែសីហា ឆ្នាំ២០២៤ **ឯកឧត្តម ណី សារាកល** អគ្គនាយករងនៃនិយ័តករបេឡាធនបាលកិច្ច (ន.ប.ធ.) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ ន.ប.ធ. អមដោយសហការី បានចូលរួមកិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពី "ការពិន័យអន្តរការណ៍ចំពោះបទល្មើសនឹងច្បាប់ស្តីពីគណនេយ្យនិងសវនកម្ម និងសេចក្តីព្រាងប្រកាសស្តីពីការដាក់តម្កល់របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុរងសវនកម្មឯករាជ្យ" ដែលរៀបចំដោយនិយ័តករគណនេយ្យ និងសវនកម្ម ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។



រូបភាព៖ កិច្ចប្រជុំកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## ពិធីអនុស្សរណៈនៃការយោគយល់គ្នារវាង ន.ប.ធ.និង ក្រុមហ៊ុន ស្ត្រងហូល ត្រាសធី ឯ.ក.

នារសៀលថ្ងៃព្រហស្បតិ៍ ១១កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ពស ២៥៦៨ ត្រូវនឹងថ្ងៃទី១៥ ខែសីហា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**), និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងក្រុមហ៊ុន ស្ត្រងហូល ត្រាសធី ឯ.ក. បានចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពី "ការប្រឹក្សាយោបល់ និងជំនួយបច្ចេកទេសសម្រាប់ការអភិវឌ្ឍបរធនបាលកិច្ចឥណទានកាបូននៅកម្ពុជា" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **លោក CHANG CHUNG-KAI** ប្រធានក្រុមហ៊ុន ស្ត្រងហូល ត្រាសធី ឯ.ក. នៅទីស្តីការ **អ.ស.ហ.**។ ការចុះអនុស្សរណៈនៃការយោគយល់គ្នានេះ មានគោលបំណងដើម្បីបង្កើតនូវក្របខណ្ឌកិច្ចសហប្រតិបត្តិការ និងយន្តការសមស្របសម្រាប់ការផ្តល់កិច្ចសហការទៅវិញទៅមកប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់ សំដៅជំរុញការអភិវឌ្ឍបរធនបាលកិច្ចឥណទានកាបូននៅកម្ពុជា តាមរយៈយន្តការប្រឹក្សាយោបល់ និងជំនួយបច្ចេកទេស។

ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នានេះ មានការអញ្ជើញចូលរួមពីតំណាងជាន់ខ្ពស់នៃនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** ថ្នាក់ដឹកនាំ និងស្ថាប័នជាដៃគូរបស់ក្រុមហ៊ុន ស្ត្រងហូល ត្រាសធី ឯ.ក. តំណាងក្រុមហ៊ុនបរធនបាល និងបុគ្គលពាក់ព័ន្ធផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច។ ពិធីនេះត្រូវបានបញ្ចប់ទៅដោយភាពរលូន និងផ្លែផ្កាខ្ពស់ ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល។




រូបភាព៖ ពិធីអនុស្សរណៈនៃការយោគយល់គ្នារវាង ន.ប.ធ. និងក្រុមហ៊ុន ស្ត្រងហូល ត្រាសធី ឯ.ក.។

## សិក្ខាសាលាពិគ្រោះយោបល់លើកទី២ លើសេចក្តីព្រាង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥"

នាព្រឹកថ្ងៃសុក្រ ១២កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើកទី២ លើសេចក្តីព្រាង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥" នៅអគារមជ្ឈមណ្ឌលអភិវឌ្ឍន៍ធុរកិច្ច (ជាន់ទី១៥) ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយឯកឧត្តមអគ្គនាយករង និងប្រធាននាយកដ្ឋាន ព្រមទាំងមន្ត្រីជំនាញនៃ **ន.ប.ធ.** និងដោយមានការចូលរួមពីក្រុមហ៊ុនបរធនបាល បរធនបាលរូបវន្តបុគ្គល ប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្រុមហ៊ុនវាយតម្លៃ និងក្រុមហ៊ុនផ្តល់សេវាសវនកម្មក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងបុគ្គលពាក់ព័ន្ធដែលផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីទទួលបានមតិយោបល់ និងធាតុចូលបន្ថែមពីតួអង្គ និងភាគីពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច ដើម្បីឱ្យការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥ កាន់តែមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយ ព្រមទាំងមានសង្គតិភាពជាមួយក្របខណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាល សំដៅដល់ការអនុវត្តប្រកបដោយសណ្តាប់ធ្នាប់ តម្លាភាព ប្រសិទ្ធភាព និងទំនុកចិត្តពីអ្នកចូលរួមក្នុងវិស័យបរធនបាលកិច្ច។



រូបភាព៖ សិក្ខាសាលាពិគ្រោះយោបល់លើកទី២ លើសេចក្តីព្រាង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំអន្តរអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ)

នាព្រឹកថ្ងៃចន្ទ ១៥កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី១៩ ខែសីហា ឆ្នាំ២០២៤ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ ន.ប.ធ. អមដោយ **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ និងសហការី បានចូលរួមកិច្ចប្រជុំអន្តរអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) ស្តីពីសេចក្តីព្រាងក្របខ័ណ្ឌនិម្មាបនកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន **កសហវ** ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិត គង់ ម៉ារី** រដ្ឋលេខាធិការ **កសហវ** និងជាអនុប្រធានប្រចាំការនៃក្រុមប្រឹក្សាបច្ចេកវិទ្យាព័ត៌មាននៃ **កសហវ** ដោយមានការអញ្ជើញចូលរួមពីបណ្តាអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទ **កសហវ** តាមប្រព័ន្ធអនឡាញ (Zoom)។



រូបភាព៖ កិច្ចប្រជុំអន្តរអគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ)។

## សិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច"

នារសៀលថ្ងៃអង្គារ ១ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២០ ខែសីហា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **លោកជំទាវ អ៊ឹម រីណា** អនុរដ្ឋលេខាធិការនៃក្រសួងយុត្តិធម៌ និងជាអនុប្រធានបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា នៅបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាប និងលើកកម្ពស់ការយល់ដឹងជាសាធារណៈ ឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់សិស្សចៅក្រម សិស្សព្រះរាជអាជ្ញា និងសិស្សសារការី ដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ, និងសិស្សចៅក្រម សិស្សព្រះរាជអាជ្ញា សិស្សអាជ្ញាសាលា និងសិស្សសារការីនៃបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា។



រូបភាព៖ សិក្ខាសាលាស្តីពី "ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធក្នុងវិស័យបរធនបាលកិច្ច"។

## វេទិកាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍ និងកសិករចិញ្ចឹមមាន់ស្រុក" នៅខេត្តត្បូងឃ្មុំ

នាថ្ងៃពុធ ២ រោចខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២១ ខែសីហា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំវេទិកាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍ និងកសិករចិញ្ចឹមមាន់ស្រុក" នៅខេត្តត្បូងឃ្មុំ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច តំណាង **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1 និង អភិបាលស្រុក និងអភិបាលរងស្រុកនៃគណៈអភិបាលស្រុកពញាក្រែក និងតំបែរ។

កម្មវិធីនេះត្រូវបានរៀបចំនៅសហគមន៍ចំនួន ២ រួមមានៈ សហគមន៍កសិកម្មតំបែរុងរឿង និងកសិករអភិរក្សពញាក្រែកតំបែរ ក្នុងគោលបំណងធ្វើការណែនាំបន្ថែមដល់សមាជិកសហគមន៍ និងភ្នាក់ងារឥណទានគម្រោង ACSEP តាមខេត្ត ស្រុក និងឃុំគោលដៅ, ផ្តល់ព័ត៌មានអំពីការផ្តល់ប្រាក់កម្ចី របស់គម្រោង ACSEP ដល់សមាជិកសហគមន៍កសិកម្មដែលមានក្នុងបញ្ជីក្រុមគោលដៅ និងកសិករចិញ្ចឹមមាន់ស្រុក និងបង្ហាញអំពីនីតិវិធីដែលអាចទទួលបានឥណទានដល់សមាជិកសហគមន៍កសិកម្ម ដែលមានបំណងស្វែងរកទុនគាំទ្រផែនការអាជីវកម្មលើវិស័យកសិកម្ម។

កម្មវិធីនេះ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តត្បូងឃ្មុំ, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តត្បូងឃ្មុំ, ក្រុមប្រឹក្សាឃុំ, និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



រូបភាពៈ វេទិកាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានដល់សមាជិកសហគមន៍ និងកសិករចិញ្ចឹមមាន់ស្រុក" នៅខេត្តត្បូងឃ្មុំ។

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

នាព្រឹកថ្ងៃសុក្រ ៤រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៤ **ឯកឧត្តម ណើ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយសហការីបានអញ្ជើញចូលរួមជាអធិបតីក្នុង "ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ជូ វណ្ណៈ** អគ្គនាយកនៃនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ នៅទីស្តីការ **អ.ស.ហ.**។



រូបភាពៈ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាងនិយ័តករអាជីវកម្មអចលនវត្ថុ និងបញ្ចាំ និងសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

## ទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍នៅប្រទេសម៉ាឡេស៊ី

ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំសហការីធ្វើទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍នៅប្រទេសម៉ាឡេស៊ី ចាប់ពី ថ្ងៃទី២២-២៣ ខែសីហា ឆ្នាំ២០២៤ ដោយបានជួបពិភាក្សាការងារជាមួយសមាគមបរធនបាលម៉ាឡេស៊ី (Association of Trust Companies Malaysia-ATCM) និងបណ្តាក្រុមហ៊ុនបរធនបាលឈានមុខមួយចំនួន រួមមាន ក្រុមហ៊ុន CIMB Commerce Trustee Berhad, ក្រុមហ៊ុន RHB Trustees Berhad, ក្រុមហ៊ុន MTrustee Berhad, ក្រុមហ៊ុន Rockwills Trustee Berhad, និងក្រុមហ៊ុន Amanahraya Trustees Berhad ពាក់ព័ន្ធនឹងកិច្ចដំណើរការអភិវឌ្ឍទីផ្សារបរធនបាលកិច្ច ក្របខណ្ឌគ្រប់គ្រងប្រតិបត្តិការ ប្រភេទផលិតផលបរធនបាលកិច្ច និងបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងវិស័យបរធនបាលកិច្ចនៅប្រទេសម៉ាឡេស៊ី ដោយមានការសម្របសម្រួលពីធនាគារ អ អេច ប៊ី ម.ក, ធនាគារ ស៊ីអាយអិមប៊ី ភីអិលស៊ី និងធនាគារ វឌ្ឍនៈ ដែលជាប្រតិបត្តិករបរធនបាលផ្តល់សេវារក្សាសុវត្ថិភាពឬរក្សាទុក ទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.**។ ជាមួយគ្នានេះ ប្រតិភូ **ន.ប.ធ.** ក៏បានចែករំលែកអំពីវឌ្ឍនភាពពីទីផ្សារបរធនបាលកិច្ច ព្រមទាំងសក្តានុពល និងកាលានុវត្តភាពនៃទីផ្សារបរធនបាលកិច្ចកម្ពុជាដល់ភាគីពាក់ព័ន្ធទាំងអស់ ក៏ដូចជាកិច្ចសហប្រតិបត្តិការនានាពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យបរធនបាលកិច្ចនាពេលអនាគត។




រូបភាព៖ ទស្សនកិច្ចសិក្សាដកស្រង់បទពិសោធន៍នៅប្រទេសម៉ាឡេស៊ី។

## ការបន្តការងារផ្សព្វផ្សាយពាក់ព័ន្ធនឹងផលិតផលឥណទាន ក្នុងគម្រោងដល់សមាជិកសហគមន៍

ចាប់ពីថ្ងៃព្រហស្បតិ៍ ៣រោចដល់ថ្ងៃសុក្រ៤រោចខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២២-២៣ ខែសីហា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងលើកកម្ពស់សុវត្ថិភាពកសិកម្ម (ACSEP-PIU1) ក្រោមក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបន្តការងារផ្សព្វផ្សាយពាក់ព័ន្ធនឹងផលិតផលឥណទានក្នុងគម្រោងដល់សមាជិកសហគមន៍ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤ ដល់សហគមន៍កសិកម្មក្ដីសង្ឃឹមកសិករ និងសហគមន៍កសិកម្មរំចេកមានជ័យ និងនៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៤ ដល់សហគមន៍កសិកម្មអូររាំងឪមានជ័យ នៅខេត្តត្បូងឃ្មុំ ក្រោមការដឹកនាំរបស់ **លោក ប៉ូ សំអាង** ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1។

កម្មវិធីនេះត្រូវបានរៀបចំក្នុងគោលបំណងធ្វើការណែនាំបន្ថែមដល់សមាជិកសហគមន៍ និងភ្នាក់ងារឥណទានគម្រោង ACSEP តាមខេត្ត ស្រុក និងឃុំគោលដៅ, ផ្តល់ព័ត៌មានអំពីការផ្តល់ប្រាក់កម្ចីរបស់គម្រោង ACSEP ដល់សមាជិកសហគមន៍កសិកម្មដែលមានក្នុងបញ្ជីក្រុមគោលដៅ និងកសិករចិញ្ចឹមមាន់ស្រុក និងបង្ហាញអំពីនីតិវិធីដែលអាចទទួលបានឥណទានដល់សមាជិកសហគមន៍កសិកម្ម ដែលមានបំណងស្វែងរកទុនគាំទ្រផែនការអាជីវកម្មលើវិស័យកសិកម្ម។

កម្មវិធីខាងលើ មានការចូលរួមដោយ សមាជិក/សមាជិកា និងទីប្រឹក្សារបស់ ACSEP PIU1, អភិបាលរងខេត្ត, អភិបាលរងស្រុក, ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តត្បូងឃ្មុំ, ក្រុមប្រឹក្សាឃុំ, មេភូមិ និងក្រុមការងារមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន ធនាគារអភិវឌ្ឍន៍ជនបទនិងកសិកម្ម និងធនាគារស្ថាបនា។



រូបភាព៖ ការបន្តការងារផ្សព្វផ្សាយពាក់ព័ន្ធនឹងផលិតផលឥណទានក្នុងគម្រោងដល់សមាជិកសហគមន៍។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8$^{th}$ Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង ន.ប.ធ. និង ក្រុមហ៊ុន អាយជី ថិក គ្រុប

នាព្រឹកថ្ងៃចន្ទ ៧រោចខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៤ ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ **(អ.ស.ហ.)** និយ័តករបរធនបាលកិច្ច **(ន.ប.ធ.)** និងក្រុមហ៊ុន អាយជី ថិក គ្រុប បានចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ស្តីពី "ការប្រឹក្សាយោបល់ និងជំនួយបច្ចេកទេសពាក់ព័ន្ធនវានុវត្តន៍បច្ចេកវិទ្យាគាំទ្រក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **លោក គឹម ពុធគីរី** ប្រធានក្រុមហ៊ុន អាយជី ថិក គ្រុប នៅមជ្ឈមណ្ឌលអភិវឌ្ឍធុរកិច្ច។ ការចុះ MoU នេះ មានគោលបំណងដើម្បីបង្កើតនូវក្របខណ្ឌកិច្ចសហប្រតិបត្តិការ សំដៅជំរុញនវានុវត្តន៍ប្រតិបត្តិការបរធនបាលកិច្ច តាមរយៈការទាញយកអត្ថប្រយោជន៍ជាអតិបរមាពីនវានុវត្តន៍បច្ចេកវិទ្យាគាំទ្រ (Technology-enabled Innovations) និងបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ។

ពិធីចុះ MoU នេះមានការអញ្ជើញចូលរួមពីតំណាងជាន់ខ្ពស់នៃនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.** ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញនៃ **ន.ប.ធ.** ថ្នាក់ដឹកនាំ និងសហការីនៃក្រុមហ៊ុន អាយជី ថិក គ្រុប តំណាងក្រុមហ៊ុនបរធនបាល និងបុគ្គលពាក់ព័ន្ធផ្តល់សេវាក្នុងវិស័យបរធនបាលកិច្ច។ ពិធីនេះត្រូវបានបញ្ចប់ទៅដោយភាពរលូន និងផ្លែផ្កាខ្ពស់ ក្រោមបរិយាកាសរីករាយ និងស្និទ្ធស្នាល។




រូបភាព៖ ពិធីចុះអនុស្សរណៈនៃការយោគយល់គ្នារវាង ន.ប.ធ. និងក្រុមហ៊ុន អាយជី ថិក គ្រុប។

## កិច្ចប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំលើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នាព្រឹកថ្ងៃចន្ទ៧រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៤ **ឯកឧត្តម ឈឺ សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច **(ន.ប.ធ.)** តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ និងសហការីបានចូលរួមកិច្ចប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំលើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាពក្រោមឱវាទ **កសហវ** តាមប្រព័ន្ធអនឡាញ Zoom។



រូបភាព៖ កិច្ចប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំលើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ប្រជុំពិភាក្សាការងាររវាង ន.ប.ធ. ជាមួយក្រសួងមហាផ្ទៃ

នារសៀលថ្ងៃចន្ទ ៧រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៦ ខែសីហា ឆ្នាំ២០២៤ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (ន.ប.ធ.) បានដឹកនាំក្រុមការងាររៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធន-បាលកិច្ច ឆ្នាំ ២០២៥-២០៣៥ ជួបប្រជុំពិភាក្សាការងារជាមួយក្រសួងមហាផ្ទៃ ដែលដឹកនាំដោយ **ឯកឧត្តម ឧត្តមសេនីយ៍ឯក ខិន ចាណាល់** អគ្គនាយករង នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល តំណាងក្រុមប្រឹក្សានីតិកម្ម និងតំណាងអគ្គស្នងការនគរបាលជាតិ អមដោយសហការី។ កិច្ចប្រជុំបានផ្តោតការពិភាក្សាអំពីបច្ចុប្បន្នភាពនៃទីផ្សារបរធនបាលកិច្ច ក្របខណ្ឌច្បាប់ក្នុងវិស័យបរធនបាលកិច្ច ប្រភេទនៃបរធនបាលកិច្ចនៅកម្ពុជាបច្ចុប្បន្ន ការគ្រប់គ្រងមូលនិធិសង្គម ការបញ្ជ្រាបការយល់ដឹងពីវិស័យបរធនបាលកិច្ចដល់អង្គការសមាគមដែលគ្រប់គ្រងមូលនិធិសង្គម និងការពិនិត្យលទ្ធភាពផ្តល់កិច្ចសហ-ប្រតិបត្តិការរវាងក្រសួងមហាផ្ទៃ និង **ន.ប.ធ.** ក្នុងគោលដៅផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក។



រូបភាព៖ ប្រជុំពិភាក្សាការងាររវាង ន.ប.ធ. ជាមួយក្រសួងមហាផ្ទៃ។

## កិច្ចប្រជុំវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តគម្រោង ACSEP សមាសភាគទី១

ថ្ងៃអង្គារ ៨ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនិងថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច ដែលជាអង្គភាពអនុវត្តគម្រោង ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំកិច្ចប្រជុំវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តគម្រោង ACSEP សមាសភាគទី១ រយៈពេល ៧ខែ ឆ្នាំ២០២៤។ កិច្ចប្រជុំប្រព្រឹត្តទៅក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជានាយកគម្រោង ACSEP-PIU1 និងមានការចូលរួមដោយ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនិយ័តករបរធនបាលកិច្ច និងជាប្រធានអង្គភាពអនុវត្តគម្រោង **ឯកឧត្តម ចាន លឹម** អគ្គនាយករងធនាគារ ARDB និងសហការី លោក Wong Keet Loong នាយកប្រតិបត្តិនៃសាជីវកម្មធានាឥណទានកម្ពុជា និងសហការី **លោក គៀង សុផល** មន្ត្រីជាន់ខ្ពស់ធនាគារស្ថាបនា និងសហការី តំណាងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងតំណាងអង្គភាពគ្រប់គ្រងគម្រោងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ កិច្ចប្រជុំបានប្រព្រឹត្តទៅតាមរបៀបវារៈដែលបានគ្រោងទុកប្រកបដោយផ្លែផ្កាខ្ពស់។



រូបភាព៖ កិច្ចប្រជុំពិភាក្សាកម្រិតថ្នាក់ដឹកនាំលើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh

www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

នារសៀលថ្ងៃអង្គារ ៨ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៤ **ឯកឧត្តម ឈី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ **លោកស្រី ឈាន សុខារី** ប្រធាននាយកដ្ឋានកិច្ចការគតិយុត្ត និងអធិការកិច្ច និងសហការី បានចូលរួមកិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពី ការធានារ៉ាប់រងខ្នាតតូច ដែលរៀបចំដោយនិយ័តករធានារ៉ាប់រង ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអនុប្រធានក្រុមប្រឹក្សា **អ.ស.ហ.** តាមរយៈប្រព័ន្ធអនឡាញ (Zoom)។




រូបភាព៖ កិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេសនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។

## សិក្ខាសាលាស្តីពី "ច្បាប់ស្តីពីបរធនបាលកិច្ច និងនិន្នាការថ្មីៗពាក់ព័ន្ធអចលនវត្ថុ"

នាព្រឹកថ្ងៃពុធ ៩រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច សហការជាមួយសភាពាណិជ្ជកម្មកូរ៉េនៅកម្ពុជា បានរៀបចំសិក្ខាសាលាស្តីពី "ច្បាប់ស្តីពីបរធនបាលកិច្ច និងនិន្នាការថ្មីៗពាក់ព័ន្ធអចលនវត្ថុ" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច និង **លោក អាន គ្យូ** ប្រធានសភាពាណិជ្ជកម្មកូរ៉េនៅកម្ពុជា នៅសណ្ឋាគារ ហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ។

សិក្ខាសាលានេះ មានគោលបំណងដើម្បីបញ្ជ្រាបការយល់ដឹងឱ្យបានកាន់តែទូលំទូលាយពីកាលានុវត្តភាព និងគុណប្រយោជន៍នៃយន្តការបរធនបាលកិច្ច ព្រមទាំងជំរុញការចូលរួមក្នុងវិស័យបរធនបាលកិច្ចរបស់សមាជិក-សមាជិកា នៃសភាពាណិជ្ជកម្មកូរ៉េនៅកម្ពុជា ដែលជាវិនិយោគិន និងធុរជនសក្តានុពលនៅកម្ពុជា ដើម្បីអាចទាញយកផលប្រយោជន៍ជាអតិបរមាពីយន្តការបរធនបាលកិច្ចសម្រាប់គម្រោងវិនិយោគ និងសកម្មភាពធុរកិច្ចរបស់ខ្លួន។



រូបភាព៖ សិក្ខាសាលាស្តីពី "ច្បាប់ស្តីពីបរធនបាលកិច្ច និងនិន្នាការថ្មីៗពាក់ព័ន្ធអចលនវត្ថុ"។

## សិក្ខាសាលាពិគ្រោះយោបល់លើកទី៣ លើសេចក្តីព្រាង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥"

នារសៀលថ្ងៃពុធ ៩រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់លើកទី៣ លើសេចក្តីព្រាង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥" នៅអគារអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្រោមអធិបតីភាពរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយឯកឧត្តមអគ្គនាយករង និងប្រធាននាយកដ្ឋាន ព្រមទាំងមន្ត្រីជំនាញនៃ **ន.ប.ធ.** និងដោយមានការចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលជាតំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់, ក្រសួងបរិស្ថាន, ក្រសួងយុត្តិធម៌, ក្រសួងមហាផ្ទៃ, ក្រសួងអប់រំ យុវជន និងកីឡា, ធនាគារជាតិនៃកម្ពុជា, គណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល, មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" តំណាងនិយ័តករ/អង្គភាពក្រោមឱវាទ **អ.ស.ហ.** និងតំណាងស្ថាប័នពាក់ព័ន្ធ។ សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីទទួលបានមតិយោបល់ និងធាតុចូលបន្ថែម

ពីស្ថាប័នរដ្ឋនិងអាជ្ញាធរពាក់ព័ន្ធ ដើម្បីឱ្យការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥ កាន់តែមានលក្ខណៈពេញលេញ និងគ្រប់ជ្រុងជ្រោយ ព្រមទាំងមានសង្គតិភាពជាមួយក្របខណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាល សំដៅដល់ការអនុវត្តប្រកបដោយសណ្តាប់ធ្នាប់ តម្លាភាព ប្រសិទ្ធភាព និងទំនុកចិត្តពីអ្នកចូលរួមក្នុងវិស័យបរធនបាលកិច្ច។



រូបភាព៖ សិក្ខាសាលាពិគ្រោះយោបល់លើកទី៣ លើសេចក្តីព្រាង "យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យបរធនបាលកិច្ច ឆ្នាំ ២០២៥-២០៣៥"។

## ពិធីសម្បថរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ចរបស់និយ័តករបរធនបាលកិច្ច

នាព្រឹកថ្ងៃព្រហស្បតិ៍ ១០ រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០២៤ មន្ត្រីអធិការកិច្ចបរធនបាលកិច្ចរបស់ **ន.ប.ធ.** ចំនួន ៨ (ប្រាំបី) រូប ដែលទទួលបាននីតិសម្បទាជានគរបាលយុត្តិធម៌ស្របតាមប្រកាសអន្តរក្រសួងលេខ ១១៣ កយ.អសហ.ប្រក/២៣ ស្តីពីការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០២៣ បានចូលធ្វើពិធីសម្បថនៅចំពោះមុខសាលាដំបូងរាជធានីភ្នំពេញ ស្របតាមមាត្រា៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

នគរបាលយុត្តិធម៌នៃ **ន.ប.ធ.** មានសិទ្ធិអំណាច ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ស្តីពីបរធនបាលកិច្ច ប្រកាសស្តីពីការបែបបទ និងនីតិវិធីនៃធ្វើអធិការកិច្ចបរធនបាលកិច្ច, ប្រកាសស្តីពីបែបបទនិងនីតិវិធីនៃការដាក់ទណ្ឌកម្មរដ្ឋបាលនិងពិន័យអន្តរការណ៍ក្នុងវិស័យបរធនបាលកិច្ច ព្រមទាំងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ចំពោះករណីសង្ស័យប្រព្រឹត្តល្មើសពាក់ព័ន្ធនឹងវិស័យបរធនបាលកិច្ចជាអាទិ៍ ការប្រព្រឹត្តល្មើសនឹងលក្ខខណ្ឌអាជ្ញាបណ្ណ/ការអនុញ្ញាត/ការចុះបញ្ជី/ការទទួលស្គាល់ពី **ន.ប.ធ.** ជាដើម។



រូបភាព៖ ពិធីសម្បថរបស់មន្ត្រីអធិការកិច្ចបរធនបាលកិច្ចរបស់និយ័តករបរធនបាលកិច្ច។

## ការប្រឡងជ្រើសរើសមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.) សម្រាប់ចូលបម្រើការងារនៅ ន.ប.ធ.

នាព្រឹកថ្ងៃសុក្រ ១១រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៤ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានរៀបចំការប្រឡងជ្រើសរើសមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) សម្រាប់ចូលបម្រើការងារនៅ **ន.ប.ធ.** ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគណៈកម្មការរៀបចំការប្រឡងជ្រើសរើសមន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.** សម្រាប់ចូលបម្រើការងារនៅ **ន.ប.ធ.** ព្រមទាំងមានការអញ្ជើញចូលរួមពី ឯកឧត្តមអគ្គនាយករង និងថ្នាក់ដឹកនាំកម្រិតនាយកដ្ឋាននៃ **ន.ប.ធ.** នៅមណ្ឌលប្រឡង សាកលវិទ្យាល័យ ពាណិជ្ជសាស្ត្រអេស៊ីលីដា ដោយមានបេក្ខជន-បេក្ខនារី បានដាក់ពាក្យចូលរួមប្រឡងប្រជែងចំនួន ២១៣រូប។

មុនពេលចាប់ផ្តើមប្រកាសបើកការប្រឡង ឯកឧត្តមអគ្គនាយកបានផ្តល់ការណែនាំដល់បេក្ខជន-បេក្ខនារី ដែលបានចូលរួមប្រឡងទាំងអស់ ត្រូវគោរព និងអនុវត្តតាមសេចក្តីណែនាំស្តីពី "ការប្រឡងជ្រើសរើសមន្ត្រីលក្ខន្តិកៈរបស់ **អ.ស.ហ.** សម្រាប់ចូលបម្រើការងារនៅ **ន.ប.ធ.**" ឱ្យបានម៉ឺងម៉ាត់ និងត្រឹមត្រូវ។ ឯកឧត្តមអគ្គនាយកក៏បានមានប្រសាសន៍ថា ការប្រឡងប្រជែងនេះគឺផ្តល់ឱកាសស្មើៗគ្នាសម្រាប់បេក្ខជន-បេក្ខនារី ទាំងអស់ ដែលឈរលើគោលការណ៍តម្លាភាព និងយុត្តិធម៌។




រូបភាព៖ ការប្រឡងជ្រើសរើសមន្ត្រីលក្ខន្តិកៈរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) សម្រាប់ចូលបម្រើការងារនៅ **ន.ប.ធ.**។

## កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

នារសៀលថ្ងៃសុក្រ ១១រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៤ **ឯកឧត្តម ណារី សាកល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) តំណាងដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** អមដោយ **លោក យុន វាសនា** ប្រធាននាយកដ្ឋានកិច្ចការទូទៅ និងសហការី បានចូលរួមកិច្ចប្រជុំត្រួតពិនិត្យការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**កសហវ**) ក្រោមអធិបតីភាពដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប** រដ្ឋលេខាធិការ **កសហវ** និងជាប្រធានក្រុមការងារថវិកាកម្រិតថ្នាក់ដឹកនាំអង្គភាពថវិកា និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័ន អង្គភាពក្រោមឱវាទ **កសហវ** នៅទីស្តីការ **កសហវ**។




រូបភាព៖ កិច្ចប្រជុំត្រួតពិនិត្យការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888